**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០០៩ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១៦

# សារាចរណែនាំ

## ស្តីពី

## នីតិវិធីនិងកិច្ចបញ្ជិកាចំណូល ចំណាយមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត

យោងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសលេខ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសលេខ៨៤៨ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតនិងការប្រព្រឹត្តទៅនៃមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ប្រកាសលេខ៩១៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតបន្ថែមគណនីនិងអនុគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីមានមូលដ្ឋានសម្រាប់អនុវត្ត និងចុះកិច្ចបញ្ជិកាគណនេយ្យចំណូល ចំណាយថវិការបស់មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរណែនាំដែលមានខ្លឹមសារដូចខាងក្រោម÷

**១.**នៅមុនដំណាច់ឆ្នាំ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យមើលការអនុវត្តចំណូល ចំណាយថវិកានិងគណនាអតិរេកបណ្តោះអាសន្នក្រៅកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋបាលរាជធានី ខេត្ត។ អតិរេកបណ្តោះអាសន្ន ជាលទ្ធផលនៃផលដករវាងសរុបទឹកប្រាក់ចំណូលថវិកា (គណនីថ្នាក់៧..) និងសរុបទឹកប្រាក់ចំណាយថវិកា (ចំណាយចរន្ត គណនីថ្នាក់៦... និងចំណាយវិនិយោគ គណនីថ្នាក់២) ដែលកើតមាននៅក្នុងឆ្នាំកំពុងអនុវត្ត។

**២.**ក្នុងករណីដែលពិនិត្យឃើញថាមានអតិរេកបណ្តោះអាសន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំប្រកាសស្តីពីការបន្ថែមឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត សម្រាប់ចំណាយឧបត្ថម្ភធនដល់មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត។

**៣.**រដ្ឋបាលរាជធានី ខេត្ត ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ចំណាយឧបត្ថម្ភធនដល់មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត។

**៤.**រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាជាចំណាយថវិកានិងផ្ទេរតួលេខឧបត្ថម្ភធនទៅគណនីប្រាក់បញ្ញើមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត នៅរតនាគារថ្នាក់កណ្តាល។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**-កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានី ខេត្ត ក្នុងគណនេយ្យថវិការាជធានី ខេត្ត÷**

ឥណពន្ធ គណនី ឧបត្ថម្ភកធនដល់ក្រសួង ស្ថាប័ន (លេខ ៦៥០១៨)

ឥណទាន គណនី ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨) និង

ឥណពន្ធ គណនី ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨)

ឥណទាន គណនី ប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២១)។

**សក្ខីបត្រ÷**

-អាណត្តិបើកប្រាក់

-ដីកាអមបញ្ចេញអាណត្តិបើកប្រាក់

-ដីកាអមលិខិតយុត្តិការ

-សលាកបត្រចុះលេខនា

-ប្រកាសបន្ថែមឥណទានថវិកា។

**បញ្ជាក់÷** -អត្ថគាហកនៅលើអាណត្តិបើកប្រាក់គឺ "មូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត"

-គណនីលេខ ៤៤១០ នៅរតនាគារថ្នាក់កណ្តាល។

**-កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានី ខេត្ត ក្នុងគណនេយ្យរដ្ឋ÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត (លេខ ៤៤០២១)

ឥណទាន គណនី ទំនាក់ទំនងរវាងរតនាគាររាជធានីខេត្តនិងរតនាគារថ្នាក់កណ្តាល (លេខ៤៣០២២)។

**សក្ខីបត្រ÷**

-ប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត

-លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត

-សលាកបត្រចុះលេខនា។

**លិខិតយុត្តិការដែលរតនាគាររាជធានី ខេត្ត ដែលត្រូវបញ្ជូនទៅរតនាគារថ្នាក់កណ្តាលមាន÷**

-ប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត

-លិខិតជូនដំណឹងឥណពន្ធ របស់រតនាគាររាជធានី ខេត្ត

-អាណត្តិបើកប្រាក់ ផ្នែកខាងក្រោម(ច្បាប់ដើម) និងដីកាអមបញ្ចេញអាណត្តិបើកប្រាក់។

**៥.** ក្រោយពីទទួលបានប្រកាសឥណទានផ្ទេរតួលេខចំណាយឧបត្ថម្ភកធនរបស់រដ្ឋបាលរាជធានី ខេត្ត ជូនមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត រតនាគារថ្នាក់កណ្តាលកត់ត្រា÷

ឥណពន្ធ គណនី ទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត (លេខ ៤៣០២១)

ឥណទាន គណនី ប្រាក់បញ្ញើមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត (លេខ ៤៤១០)។

**សក្ខីបត្រ÷**

-លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត

-ប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត

-លិខិតជូនដំណឹងឥណពន្ធ ឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា

-អាណត្តិបើកប្រាក់ ផ្នែកខាងក្រោម(ច្បាប់ដើម) និងដីកាអមបញ្ចេញអាណត្តិបើកប្រាក់។

**៦.**សមតុល្យនៃគណនីប្រាក់បញ្ញើមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត ត្រូវយោងទៅឆ្នាំបន្ទាប់។

**៧.**នៅឆ្នាំបន្ទាប់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំប្រកាសបន្ថែមឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត សម្រាប់ចំណាយអភិវឌ្ឍន៍។

**៨.**បន្ទាប់ពីទទួលបានប្រកាសស្តីពីការបន្ថែមឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត ត្រូវកែតម្រូវផែនការលទ្ធកម្មប្រចាំឆ្នាំ មុនដំណើរការអនុវត្តកិច្ចលទ្ធកម្ម។

**៩.**យោងប្រកាសស្តីពីការបន្ថែមឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត រតនាគារថ្នាក់កណ្តាលរៀបចំប្រកាសឥណទានផ្ទេរវិភាជន៍ថវិកាពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត និងកត់ត្រា÷

ឥណពន្ធ គណនី ប្រាក់បញ្ញើមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្ត (លេខ ៤៤១០)។

ឥណទាន គណនី ទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្តាលនិងរតនាគាររាជធានី ខេត្ត (លេខ៤៣០២១)។

**សក្ខីបត្រ÷**

-លិខិតជូនដំណឹងឥណពន្ធ របស់រតនាគារថ្នាក់កណ្តាល

-ប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល

-សលាកបត្រចុះលេខនា

-ប្រកាសបន្ថែមឥណទានថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១០.**នៅពេលទទួលបានប្រកាសឥណទានផ្ទេរវិភាជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ពីរតនាគារថ្នាក់កណ្តាល រតនាគាររាជធានី ខេត្ត កត់ត្រា÷

**-កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានីខេត្ត ក្នុងគណនេយ្យរដ្ឋ÷**

ឥណពន្ធ គណនី ទំនាក់ទំនងរវាងរតនាគាររាជធានី ខេត្តនិងរតនាគារថ្នាក់កណ្តាល (លេខ ៤៣០២២)

ឥណទាន គណនី ប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត (លេខ ៤៤០២១)។

**សក្ខីបត្រ÷**

-ប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល

-លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត

-លិខិតជូនដំណឹងឥណទានរបស់រតនាគាររាជធានី ខេត្ត

-សលាកបត្រលេខនា។

**-កិច្ចបញ្ជិកាគណនេយ្យរបស់រតនាគាររាជធានី ខេត្ត ក្នុងគណនេយ្យថវិការាជធានី ខេត្ត÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២១)

ឥណទាន គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន (លេខ ៧៥០១១)។

សក្ខីបត្រ÷

- លិខិតជូនដំណឹងឥណពន្ធរបស់រតនាគាររាជធានី ខេត្ត
- លិខិតជូនដំណឹងឥណទានរបស់រតនាគាររាជធានី ខេត្ត
- សលាបត្រចុះលេខនា។

**១១.**រដ្ឋបាលរាជធានី ខេត្ត ត្រូវដំណើរការចំណាយថវិកា រីឯរតនាគាររាជធានី ខេត្តត្រូវដំណើរការទូទាត់និងចុះកិច្ចបញ្ជិកាគណនេយ្យតាមនីតិវិធីហិរញ្ញវត្ថុនិងគណនេយ្យជាធរមាន។

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុវត្តសារាចរនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

“ដើម្បីជូនជ្រាប”

- ឯកសារ- កាលប្បវត្តិ